# មជ្ឈមណ្ឌលឯកសារកម្ពុជា

**ករណី សោម ម៉ែត ភេទប្រុស K05435**

**សម្ភាសជាមួយ សោម ម៉ែត អាយុ៤៣ឆ្នាំ ភេទប្រុស ជាម្ចាស់ប្រវត្តិរូប**

**មុខងារសម័យខ្មែរក្រហមៈ កងការពារនៅមន្ទីរស-២១**

**នៅភូមិកំពង់សំបួរលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល**

**នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២**

**សម្ភាសដោយៈ អ៊ីសា ខស្មាន**

**សរុបៈ ២៣ទំព័រ**

**(កាសែ្សតនេះចាប់ផ្តើមពីខាង**៣**មុន)**

ខស្មានៈ ពូ ខ្ញុំសុំស្គាល់ឈ្មោះពូ?

ម៉ែតៈ សោម ម៉ែត ។

ខស្មានៈ ពូអាយុប៉ុន្មាន?

ម៉ែតៈ ៤៣ ។

ខស្មានៈ សព្វថ្ងៃពូនៅភូមិឃុំស្រុកអី?

ម៉ែតៈ សព្វថ្ងៃហ្នឹងអី?

ខស្មានៈ បាទ!

ម៉ែតៈ នៅភូមិកំពង់សំបួរលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។

ខស្មានៈ ចុះទីកន្លែងដែលលោកពូកើត?

ម៉ែតៈ កើតនៅភូមិព្រែកស្រុក ឃុំព្រែកស្តី ស្រុកកោះធំ ។

ខស្មានៈ ហៅភូមិព្រែកមេស្រុក?

ម៉ែតៈ បាទ ។

ខស្មានៈ ពូខ្ញុំចង់ដឹងពីចន្លោះថ្ងៃ១៧ ខែមេសា ពេលដែលខ្មែរក្រហមក្រហមចូលកាន់កាប់ក្រុង ភ្នំពេញ ហ្នឹង ១៧ មេសា ៧៥ ហ្នឹង រហូតដល់ថ្ងៃបែកគឺថ្ងៃ៦ មករា ១៩៧៩ ហ្នឹង។ ក្នុងរយៈ ពេលបីឆ្នាំ ប្រាំបីខែម្ភៃថ្ងៃហ្នឹង តើពូដែលបានឃើញអ្នកណាម្នាក់សម្លាប់មនុស្ស ទេ?

ម៉េតៈ សម្លាប់?

ខស្មានៈ បាទ បាទ។

ម៉េតៈ សម្លាប់មានតែឌុច អាប៉េងអីហ្នឹង ហើយភ៉ាន់ បងប្អូនគេហ្នឹង។

ខស្មានៈ ប៉េងធ្វើការអីដែរ?

ម៉េតៈ ប៉េង គេខាងប្រធាន“គ” ។

ខស្មានៈ ប្រធាន“គ” នៅណា?

ម៉េតៈ នៅទួលស្លែង។

ខស្មានៈ ហើយចុះភ៉ាន់?

ម៉េតៈ ភ៉ាន់ហ្នឹងគេខាងយាមផង ការពារផង ធម្មតាដូចក្បែរផ្លូវ ក្បែរអីហ្នឹង។

ខស្មានៈ ប៉េង ភ៉ាន់ មានស្រុកកំណើតនៅណា?

ម៉េតៈ ប៉េង ភ៉ាន់ បើនិយាយរឿងស្រុកកំណើត ខ្ញុំអត់បាន ព្រោះអីខ្ញុំភ្លេចអស់ហើយ ដូចខ្ញុំនិយាយ អីចឹង។

ខស្មានៈ ហើយនៅរស់ទេ?

ម៉េតៈ ពីរនាក់ហ្នឹង បងប្អូនគេហ្នឹងសុទ្ធតែនៅរស់។

ខស្មានៈ នៅកន្លែងណា?

ម៉េតៈ កាលចេញទៅ ខ្ញុំដឹងថានៅ តែរឿងចេញផុតហើយមិនដឹងថានៅណាទៀត។

ខស្មានៈ បាទ ចុះក្រៅពីប៉េង ភ៉ាន់ ពូដែលឃើញអ្នកណាផ្សេងទៀតសម្លាប់មនុស្សទេ?

ម៉េតៈ ប៉េង ភ៉ាន់ ហើយ វាមាន។ តែអ្នកសម្លាប់នោះវាងាប់អស់ដែរហើយ ងាប់បន្តកន្ទុយគ្នា

ខស្មានៈ បា ខ្ញុំគ្រាន់តែចង់ដឹងឈ្មោះ។

ម៉េតៈ ប៉េង ភ៉ាន់ (ឈប់មួយសន្ទុះ) កំពុងរកនឹកសិន ព្រោះអីអ្នកគេអោយធ្វើអញ្ចឹងច្រើនតែ អ្នកទុកចិត្តផង់គេហើយណា៎។

ខស្មានៈ បាទ បាទ។

ម៉េតៈ   រកនឹកមិនឃើញ ទាល់តែខ្ញុំព្រាងទុក បានដឹង ។ នឹកអត់ឃើញទេ ។

ខស្នានៈ អត់អីទេ ចាំខ្ញុំមកក្រោយទៀត ។ ពូបានឃើញហេតុកាណ៍នៅពេលណា?

ម៉េតៈ   បាទ? ហេតុការណ៍ដែលគេសម្លាប់នោះហេ?

ខស្នានៈ បាទ នៅពេលណា នៅឆ្នាំណា ដែលថា ប៉េង និង វ៉ាន់ សម្លាប់?

ម៉េតៈ   ឆ្នាំ៧៧ ។

ខស្នានៈ ថ្ងៃខែ ចាំទេ?

ម៉េតៈ   អត់ចាំទេ ។ រឿងថ្ងៃខែខ្ញុំអត់បានចាំទេ ។

ខស្នានៈ អាចចុងឆ្នាំ៧៧ ដើមឆ្នាំ ឬពាក់កណ្ដាលឆ្នាំ?

ម៉េតៈ   វា៧៧-៧៨ហ្នឹង ។

ខស្នានៈ ៧៧ ឬ៧៨?

ម៉េតៈ   និយាយទៅ ៧៨ ខ្ញុំម៉ារយៈហ្នុងគេដកខ្ញុំដូចថាចេញចូល ចេញចូលៗរហូតនោះណា តិចទៅគេអោយខ្ញុំទៅធ្វើស្រូវទៅ តិចទៅគេអោយខ្ញុំមកវិញម៉ ហើយកន្លែងនោះដូចដឹងស្រាប់ ហើយបងខ្ញុំក៏គេយកវៃចោល ។

ខស្នានៈ ពូ រឿងដែលប៉េង ហើយនិងវ៉ាន់ សម្លាប់មនុស្សនោះ ពូគ្រាន់តែឃើញច្បាស់នឹងភ្នែក ឬក៏គ្រាន់តែឮ?

ម៉េតៈ   ខ្ញុំឃើញបណ្ដើរចេញម៉ោ ព្រោះអីខ្ញុំនៅកន្លែងសេដ្ឋកិច្ច ព្រលប់ៗហ្នឹងណាំ ឃើញគេបណ្ដើរចេញទៅ មករកចន្លោះដើមអំពិលបារាំង ។

ខស្នានៈ នៅកន្លែងណា?

ម៉េតៈ   ត្រង់កែងគុក ។

ខស្នានៈ គុកអី?

ម៉េតៈ   គុកទួលស្លែងយើងហ្នឹង ។

ខស្នានៈ កាលជំនាន់នោះ ហៅឈ្មោះកន្លែងនោះថាម៉េច?

ម៉េតៈ   កន្លែងនោះបើនិយាយគេថា ស-២១ ។

ខស្នានៈ ពូគ្រាន់តែបានឃើញបណ្ដើរ?

ម៉េតៈ   ឃើញបណ្ដើរទៅ ។ ប៉ុន្តែ បណ្ដើរទៅមានរឿងអីថាអត់វៃទេ បើតួនាទីទៅហើយ ។

ខស្នានៈ បណ្តើរនោះបណ្តើរអ្នកណា?

ម៉េតៈ អត់ស្គាល់ទៀត ។ ព្រលប់ៗទៅហើយ ធម្មតាខ្ញុំគេមិនសូវអោយចូលទៅក្នុងទេ ។

ខស្នានៈ បណ្តើរចូល ឬបណ្តើរចេញ?

ម៉េតៈ បណ្តើរចេញ ។

ខស្នានៈ ចឹង អ្នកនោះអ្នកទោស ឬប្រជាជនធម្មតា ឬជាស្មី? ដែលប៉េង វ៉ាន់បណ្តើរចេញទៅនោះ?

ម៉េតៈ បណ្តើរចេញទៅនោះ ហ្នឹងអ្នកទោស ។

ខស្នានៈ ពូស្គាល់យ៉ាងម៉េចបានថាអ្នកទោស?

ម៉េតៈ ចុះបើឃើញគេចងមុខបណ្តើរចេញទៅ បានដឹងថាអ្នកទោសហើយ ធម្មតាអ្នកអត់ទោស មាន អ្នកណាគេចងមុខចងដៃអីចឹងទេ ។

ខស្នានៈ ស-២១ ហ្នឹង សុំពូបញ្ជាក់ទីកន្លែងមើល នៅកន្លែងណា?

ម៉េតៈ ស-២១ បើនិយាយទៅវាជាប់ខ្សែរយៈវាហ្នឹងពីព្រៃស មកកន្លែងទួលស្លែងហ្នឹង អាហ្នឹងវា រួមគ្នាហ្នឹងទាំងអស់ ពួកវាហ្នឹង រួមគ្នាទាំងអស់ ។

ខស្នានៈ ចុះក្រៅពីប៉េង និងវ៉ាន់ មានប៉ុន្មាននាក់ទៀតដែលបានបណ្តើរអ្នកទោសដែរនោះ ពូអត់ ចាំឈ្មោះក៏ដោយ មានប៉ុន្មាននាក់?

ម៉េតៈ អត់បានចាំឈ្មោះទេ ។

ខស្នានៈ គ្រាន់តែចង់ដឹងពីអ្នកដែលបណ្តើរ(អ្នកទោស) មានប៉ុន្មានអ្នក?

ម៉េតៈ ជួនកាលបីនាក់ ហើយបើចុងក្រោយ៧៨-៧៩ហ្នឹង គេលែងអោយពួកខាងនិរតីហើយ គេ អោយពួកខាងកំពង់ឆ្នាំងម្តងហើយ ។ គេអោយសម្លាប់ ច្រើនតែអ្នកខាងកំពង់ឆ្នាំង ។

ខស្នានៈ អ្នកដែលសម្លាប់គេ?

ម៉េតៈ បាទ ពួកកូនចៅឌុចហ្នឹងផ្ទាល់ ។

ខស្នានៈ ឆ្នាំណា?

ម៉េតៈ ៧៨ និង ៧៩ ហ្នឹងណា ។

ខស្នានៈ ហើយចុះប៉េង និងវ៉ាន់?

ម៉េតៈ ៧៨ គេជិតស្និទធម្មតាគេទាក់ទងអ្នកធំគ្នាគេណា៎ អាហ្នឹងដូចមានខ្សែគេ គេធ្វើការងារ បានល្អ គេជិតស្និទ្ធនឹងគ្នាគេទៅ គេទុកទៅ អ្នកណាសមាសភាពមិនល្អគេដកចេញអោយ ឆ្ងាយផុតពីមុខពីមាត់គេ ដូចថាគ្រាន់តែខ្សែក្រវ៉ាត់ការពារ ។

ខស្មានៈ ពូ ខ្ញុំចង់បញ្ជាក់បន្តិច ត្រង់ពូនិយាយថាឃើញចងមុខអ្នកទោសបណ្តើរចេញទៅ ហេតុអីពូថាយកទៅសម្លាប់ បើពូបានឃើញតែប៉ុណ្ណឹង?

ម៉េតៈ ទៅហើយបាត់ៗ ហើយឮសូរថាគេយកទៅសម្លាប់ៗ ។

ខស្មានៈ អ្នកណានិយាយអីចឹង?

ម៉េតៈ និយាយនោះសុទ្ធតែគ្នាឯងនៅរោងបាយហ្នុង ។

ខស្មានៈ ឈ្មោះអី?

ម៉េតៈ គ្រាន់តែគាត់ស្លាប់ដែរហើយ គ្រូខ្ញុំដែរទេ បងគឿ នៅព្រែកស្តីនេះ ។

ខស្មានៈ ឈ្មោះល្បងគឿ?

ម៉េតៈ ឈ្មោះកំណើតគឿ ហៅ នាង ។

ខស្មានៈ នៅភូមិព្រែកស្តី?

ម៉េតៈ បាទ នៅភូមិព្រែកស្តី ម្តុំផ្ទះថ្ម ជិតផ្សារ ។

ខស្មានៈ គាត់ស្លាប់ពេលណា?

ម៉េតៈ គាត់ស្លាប់ ៧៨-៧៩ ហ្នឹងដែរណា៎ ។ ខ្ញុំពិបាករឿងចំណាំដល់ហើយឥឡូវ ។

ខស្មានៈ ហេតុអីបានគាត់ស្លាប់?

ម៉េតៈ មិនដឹងជាគេចោទគាត់រឿងដាំបាយយ៉ាងម៉េចអីយ៉ាងម៉េចទេ ។

ខស្មានៈ ចឹងពូឮតាមរយៈគាត់នោះហើយដែលថាមនុស្សយកចេញទៅយកទៅសម្លាប់?

ម៉េតៈ បាទ ។

ខស្មានៈ ពូមានដឹងទេថា អ្នកទាំងនោះត្រូវគេសម្លាប់តាមរបៀបយ៉ាងម៉េច?

ម៉េតៈ អារឿងសម្លាប់ ខ្ញុំអត់បានទៅដល់ផ្ទាល់ទេ គ្រាន់តែបានឃើញបានឮគេបណ្តើរអីចឹងណា៎

ខស្មានៈ ចុះមានដែលឮគេថាសម្លាប់មនុស្សដោយវិធីណាទេ?

ម៉េតៈ អត់ អត់ដែលឮសូរ ។

ខស្មានៈ ហើយអ្នក(ទោស) ដែលបណ្តើរចេញទៅមានដែលឃើញយកចូលវិញទេ?

ម៉ែតៈ  អត់ ។

ខស្មានៈ ដែលពូប៉េង  ហើយនិងវ៉ាន់  ឬក៏ជនដែដល់ហ្នឹងបាននិយាយថាមូលហេតុអីបានជាគាត់  សម្លាប់មនុស្សទេ?

ម៉ែតៈ  ខ្ញុំវាអត់មានយល់ទេ ។

ខស្មានៈ មានដែលនិយាយទេ?

ម៉ែតៈ  អត់ទេ  អត់ដែលបានជួបគ្នានិយាយគ្នាអីទេ  រឿងធ្វើការចឹង  បើហ៊ាននិយាយគ្នា  មិនស្រួលនោះគេថាយើងបំផុសបំផុលចលនាអី  សុទ្ធតែស្ងាត់ស្ងៀមទាំងអស់ ។

ខស្មានៈ ពូ  ខ្ញុំចង់ដឹងថាប៉េង  និង  វ៉ាន់  ជាកម្មាភិបាលខ្មែរក្រហម  ឬយ៉ាងម៉េច?

ម៉ែតៈ  កាលជំនាន់នោះ  ខ្ញុំវាអត់សូវយល់អីដែរ ។

ខស្មានៈ អ្នកណាដែលគ្រប់គ្រងលើប៉េង  ហើយ  វ៉ាន់?

ម៉ែតៈ  មានតែឌុច  និងហ៊ិ ។

ខស្មានៈ ហើយឌុច  និងហ៊ិ  ជាកម្មាភិបាលខ្មែរក្រហមទេ?

ម៉ែតៈ  បាទ  គាត់នោះបើនិយាយទៅ  វាពិបាកយល់ដែរខ្ញុំនោះ  វាអត់សូវយល់ហ្នឹងគេ ។  ណា  មួយវាអត់ចេះទ្រឹស្តីរឿងអីៗហ្នឹងគេ  រកយល់មិនកើត ។

ខស្មានៈ ប៉េង  ហើយនិងវ៉ាន់  ពូហ៊ានថាជាខ្មែរក្រហមដែរឬក៏យ៉ាងម៉េច?

ម៉ែតៈ  និយាយទៅមានតែខ្មែរក្រហមហ្នឹងហើយ ។

ខស្មានៈ ពូដឹងយ៉ាងម៉េច  ហេតុអីបានពូដឹងថាប៉េង  ហើយនិងវ៉ាន់ជាកម្មាភិបាលខ្មែរក្រហម?

ម៉ែតៈ  ព្រោះអី  គេដូចថាខ្សែតាឌុច  គេចាត់តាំង  ចាត់តាំងអោយមើលខុសត្រូវ  ដូចជាកូនចៅ  ដូចជាខ្ញុំឋានៈជាយុទ្ធជនអីចឹងណា៎  អាហ្នឹងវាចឹងទេ ។

ខស្មានៈ ចុះនៅពីលើឌុចមានអ្នកណាទៀត?

ម៉ែតៈ  លើឌុចទៀតខ្ញុំលែងដឹងសោះហើយ ។

ខស្មានៈ អ្នកណាដែលជាអ្នកបញ្ជាអោយឌុចធ្វើស្អីៗ?

ម៉ែតៈ  អត់  ខ្ញុំអត់ដឹង ។  ខ្ញុំដឹងត្រឹមតែថាឌុចធ្វើមេនៅហ្នឹង ។

ខស្មានៈ ចុះមនុស្ស  មុនពេលយកទៅសម្លាប់  តើមានការជំនុំជម្រះក្តីទេ?

ម៉ែតៈ  អត់  អត់ដឹងទេរឿងគេ ។

ខស្មានៈ ពូដែលស្គាល់ឈ្មោះជនរងគ្រោះ បានន័យថាអ្នកទោស ពូមានដែលស្គាល់ទេ? ពូមានស្គាល់អ្នកទោសណាម្នាក់ទេក្នុងចំណោមអ្នកទោសដែលពូបានឃើញគេយកចេញទៅ នោះ?

ម៉េតៈ ខ្ញុំស្គាល់តែតានេះមួយ ឈ្មោះតាតួន ។

ខស្មានៈ តាតួននៅណា?

ម៉េតៈ នៅវត្តជ្រុងរមាស ។

ខស្មានៈ ជាភូមិឬ?

ម៉េតៈ ជាវត្ត លោកគង់នៅវត្តហ្នុង ។

ខស្មានៈ ឃុំស្រុកអីដែរ?

ម៉េតៈ ឃុំកំពុងកុង ស្រុកកោះធំនេះដែរ ។

ខស្មានៈ ពូបានឃើញតាតួនយ៉ាងម៉េចខ្លះ?

ម៉េតៈ តាតួនគាត់ធ្វើនិរសាវត្តលោកណា៎ ដល់ហើយមិនដឹងគាត់មានរឿងអី គេយកទៅនោះ ។

ខស្មានៈ យកទៅស-២១?

ម៉េតៈ បាទ ។

ខស្មានៈ ហើយមានឃើញយកចេញវិញទេ?

ម៉េតៈ អត់ឃើញយកចេញ ។

ខស្មានៈ តាតួនមានស្គាល់ពូទេ?

ម៉េតៈ អត់ទេ និយាយអោយត្រង់ទៅ ខ្ញុំគ្រាន់តែដើរចុះដើរឡើងយាមតែរបងហ្នុង បើខ្ញុំចូល ផ្ទាល់គេម៉េចអោយខ្ញុំចូល សុទ្ធតែលាក់ការណ៍សម្ងាត់ផស់គេទាំងអស់ ។

ខស្មានៈ តាតួននោះគេចាប់ពីកន្លែងណាទៅ?

ម៉េតៈ អត់ឃើញទេ ស្រាប់តែឃើញ ។

ខស្មានៈ នៅឆ្នាំណា?

ម៉េតៈ តាតួនខ្ញុំឃើញនៅក្នុងឆ្នាំ៧៨ហើយ ។

ខស្មានៈ ខែ?

ម៉េតៈ អត់ដឹងខែទេ ។

ខស្មានៈ ក្រៅពីតាតួនមានស្គាល់អ្នកណាទៀតទេ?

ម៉ែត: វាភ្លេចភ្លាំងអស់ហើយឥឡូវហ្នឹងខ្ញុំ ។

ខស្មានៈ ពេលចាប់ទៅនោះ គាត់សឹកធម្មតាហើយឬនៅ ឬមួយនៅជាលោកសង្ឃដដែល?

ម៉ែត: សឹកហើយ ស្លៀកពាក់ធម្មតា ។

ខស្មានៈ ចុះកាលមុនគាត់លោកសង្ឃ?

ម៉ែត: បាទ គាត់ជាលោកសង្ឃ ។

ខស្មានៈ គាត់ជាលោកសង្ឃនៅពេលណា?

ម៉ែត: កាលគាត់លោកសង្ឃ ខ្ញុំនៅក្នុងវត្ត ហើយខ្ញុំខស្សាហ៍ទៅវត្តជ្រុងរមាសជាជាមួយលោក គាសួង បានខ្ញុំស្គាល់គាត់ ។

ខស្មានៈ ពូនៅវត្តណា?

ម៉ែត: នៅវត្តព្រែកស្តី ។

ខស្មានៈ កាលនោះនៅឆ្នាំណា?

ម៉ែត: ឆ្នាំ៦៩ ។ ខ្ញុំនៅជាមួយលោកគាសួង ហើយលោកគាសួងខស្សាហ៍និមន្តទៅលេងវត្ត ជ្រុងរមាសហ្នឹង ឃើញស្គាល់គាត់ ។

ខស្មានៈ លោកពូ មានអ្នកណាទៀតដែលបានឃើញ ឬដឹងហេតុការណ៍ដូចលោកពូនិយាយនេះ?

ម៉ែត: ដូចជាអត់ ។ ដូចជាភ្លេចជាភ្លាំងអស់ហើយណ៎ា ។

ខស្មានៈ នឹកមើល ក្រែងលោមានអ្នកណាដឹងរឿងហ្នឹងដែរ?

ម៉ែត: ភ្លេចទៅ ភ្លេចអស់ហើយ រកនឹកមិនឃើញ បែកគ្នាយូរទៅ គ្រាន់តែដើរដល់គ្នាក៏លែងស្គាល់គ្នាដែរឥឡូវហ្នឹង?

ខស្មានៈ ពូ ពីរឿងយកមនុស្សចេញពីស-២១ ឬយកមនុស្សចូលស-២១ ពូមានដែលឃើញរបាយការណ៍ ដូចជាប៉េង ឬវ៉ាន់ ឬអ្នកណាក៏ដោយបានសរសេររបាយការណ៍ពីរឿង ហ្នឹងផ្ញើរទៅអ្នកណាមួយទេ?

ម៉ែត: អត់ដែលឃើញទេ ។

ខស្មានៈ ចូលមកដល់ចំណុចមួយទៀត នៅក្នុងពេលហ្នឹងដដែលគឺ៣ឆ្នាំ៨ខែ២០ថ្ងៃហ្នឹង ពីថ្ងៃ១៧ មេសា ៧៥ ដល់ថ្ងៃ៦ មករា ៧៩ហ្នឹង តើពូបានឃើញអ្នកណាម្នាក់បង្កអោយអ្នកណាម្នាក់ទៀតឈឺចាប់ និយាយអោយចំហៅថាទារុណកម្ម?

ម៉ែតៈ  រឿងមាន ចេះតែមានហើយ ប៉ុន្តែខ្ញុំមិនបានចំណាំមុខ ពេលនោះសុទ្ធតែមានទាំងអស់ ហើយ ។

ខស្មានៈ ពូឃើញ ឬពូត្រូ?

ម៉ែតៈ  និយាយអញ្ចេះ ខ្ញុំនិយាយត្រង់ហើយណ៎ា ខ្ញុំដូចថាបញ្ជូនបានបញ្ជូនអីយកទៅអោយអ្នក ទោសហូបអីចឹងណ៎ា គ្រាន់តែប៉ុណ្ណឹងទេ អារឿងអោយដឹងត្រូយ៉ាងម៉េចៗដូចថាកន្លែងណា គេសួរកន្លែងណាគេចាប់ កន្លែងណាគេចង ខ្ញុំអត់បានដឹងទេ ។

ខស្មានៈ ពូចាប់ផ្តើមយកបាយអោយអ្នកទោសនៅពេលណា?

ម៉ែតៈ  កាលហ្នុង នៅក្នុងឆ្នាំ៧៧អីហ្នឹងទេ ។

ខស្មានៈ ពូបានឃើញរយៈពេលប៉ុន្មានឆ្នាំ?

ម៉ែតៈ  ខ្ញុំបានឃើញតែ៧៧ ដល់៧៨គេដកខ្ញុំចេញម៉ោ ដល់អាពេលគេអោយខ្ញុំមកធ្វើស្រូវនៅបឹងទំពុនហ្នឹង ខ្ញុំចេះតែត្រូសួរដំណឹងហ៊ុយថា ហ៊ុ ចាប់ហ៊ុយធំហើយ ។ ចាប់ហ៊ុយធំ អញ្ចឹងមានតែគ្នាឯងលេងគ្នាឯងហ្អេ?

ខស្មានៈ ហ៊ុយធំយ៉ាងម៉េច?

ម៉ែតៈ  ហ៊ុយប្រធានអាកន្លែងព្រៃសហ្នឹង ធ្វើស្រែហ្នឹង អាហ្នឹងដូចថាអ្នកធំចាប់អ្នកធំហើយហ្នឹង ។

ខស្មានៈ ពូឃើញសភាពអ្នកទោសយ៉ាងម៉េច ពេលពូយកបាយទៅអោយ?

ម៉ែតៈ  គ្រាន់តែឃើញនោះធ្លាក់ថ្លើមក្តុកហើយ ពិបាកមើលណាស់ ធម្មតានៅក្នុងគុកហើយ វាពិបាកវេទនា អាដែងគេធ្វើទារុណកម្មនោះណ៎ា ។ ដល់ពេលខ្ញុំទៅ ខ្ញុំដើរដាក់បាយអោយ ដល់ពេលនេះបានខ្ញុំប្រមូលចានមកវិញ ។

ខស្មានៈ យ៉ាងម៉េចទៀត សុំពូរៀបរាប់អោយអស់មកមើល? អ្នកទោសនោះយ៉ាងម៉េចខ្លះ?

ម៉ែតៈ  ធម្មតាតែនៅក្នុងហ្នុង ពិបាកវេទនាអីចឹងទៅ ។

ខស្មានៈ គេដាក់យ៉ាងម៉េច?

ម៉ែតៈ  គេអោយនៅម៉ាបន្ទប់មួយៗ ហើយគេដាក់ខ្នោះសឹកដែក ហើយខ្ញុំចេះតែជញ្ជូនកន្ថោ យកចាក់ចោល គេបញ្ជារអោយយើងធើ យើងចេះតែធើទៅ ។ វាមានឋានៈវា ដូចថា អ្នកណាមានប្រវត្តិរូបល្អគេចាត់តាំងអោយទៅខាងសួរអីចឹងទៅ ខាងចាប់ខាងចងអីចឹងទៅ ខាងបណ្តើរអីចឹងទៅ យើងប្រវត្តិរូបមិនល្អ គេចាត់តាំងយើងអោយទៅខាងសេដ្ឋកិច្ច យាមកាមជុំវិញ បម្រើទឹកអីចឹងទៅ ។

ខស្នាន: ចុះបាយអោយ(អ្នកទោស)យ៉ាងម៉េច ម៉ាងៃប៉ុន្មានពេល?

ម៉េត: វាមានឋានៈគេទៀត បើអ្នកធំនោះ មានអ្នកយកបាយអោយអ្នកធំផ្សេងអីចឹងទៅ ។

ខស្នាន: ចុះពូ?

ម៉េត: ខ្ញុំយកទៅអោយដូចជាគណៈកងអីដូចគេដាប់កន្លែងហ្នុងដែរ ។

ខស្នាន: ខ្ញុំចង់ដឹងពីរបបបាយមួយថ្ងៃប៉ុន្មានពេល?

ម៉េត: បាយ មួយថ្ងៃពីរពេល ព្រឹកល្ងាច ។

ខស្នាន: ប៉ុនណាដែរ?

ម៉េត: តាមបាយនោះដូចថាហូបឆ្អែត ។

ខស្នាន: ចុះម្ហូប?

ម៉េត: ម្ហូបចេះតែស្លម្ជូរចេកអី ចេះតែដាក់ទៅ ។

ខស្នាន: ម្ហូបនោះ ម្ហូបកម្មាភិបាលនៅកន្លែងនោះផ្សេងទៀត ឬក៏ម្ហូបដូចគ្នា?

ម៉េត: ម្ហូបផ្សេងគ្នា ។ ម្ហូបអ្នកទោសអន់ជាង មិនដូចគ្នាទេ ។ ហើយសុទ្ធតែដាក់ធុងដើរដួស ហើយ ។

ខស្នាន: ហើយចុះទឹក?

ម៉េត: ទឹកដួសយកទៅអោយធម្មតា ។

ខស្នាន: អញ្ចឹងសភាពអ្នកទោសមានស្គមស្គាំងទេ?

ម៉េត: ស្គមស្គាំងដោយកន្លែងដែរ ។

ខស្នាន: ដោយកន្លែងយ៉ាងម៉េចទៅ?

ម៉េត: ដូចកន្លែងណាដែលគេធ្វើទារុណកម្មខ្លាំង ស្គមស្គាំង ហូបបាយអត់បាន ។

ខស្នាន: ពូឃើញអ្នកទោសដូច្នេះនៅកន្លែងណា?

ម៉េត: អ្នកទោស?

ខស្នាន: បាទអ្នកទោសដែលលោកពូយកបាយអោយ?

ម៉េត: នៅកន្លែងទួលស្លែងយើងហ្នឹង ។

ខស្នាន: ក្រៅពីហ្នឹងមានដែលយកបាយអោយអ្នកទោសនៅកន្លែងណាផ្សេងទៀតទេ?

ម៉េត: អត់ ។

ខស្នាន: ពូមានដែលយកបាយទៅអោយ ហើយមានស្គាល់គ្នាទេ?

ម៉េត: ជួប ជួបតែមេខ្ញុំម្នាក់ ។ គាត់ជាវរសេនាតូច បងភី ។

ខស្នាន: ស្អីភី?

ម៉េត: មិនដឹងស្អីភីដែរ ។

ខស្នាន: គាត់ជាប្រធានវរសេនាតូច ឬក៏ធ្វើអីនៅក្នុងវរសេនាតូច?

ម៉េត: គាត់ជាប្រធានវរសេនាតូច ៧០៣ យើងហ្នឹងណា ។ ហើយកាលឡើយខ្ញុំមិននិរសារគាត់ ។ ដល់ពេលខ្ញុំឃើញអីចឹង ខ្ញុំស្រងាកចិត្តយ៉ាងម៉េចទេ ខ្ញុំខ្លាចចូលខ្លួនឯងទៀតហ្នឹង ខ្លាចគេស្រាវជ្រាវរកខ្សែអញ្ចេះៗ ។

ខស្នាន: វរសេនាតូចលេខប៉ុន្មាន?

ម៉េត: ដូចជាវរសេនាតូច ៧០៣ ។

ខស្នាន: ក្រែងថា ៧០៣ ជាកងពល?

ម៉េត: អត់ទេ ៧០៣ ទើបកើតក្រោយបែកភ្នំពេញនេះទេ កាលមុននោះមានវរសេនាតូច ៧០៣ ដែរណា៎ នៅក្នុងកងពល១២ ។

ខស្នាន: ពូបានឃើញនៅពេលណា ឆ្នាំណា?

ម៉េត: ឆ្នាំ៧៨ ។

ខស្នាន: ខែ?

ម៉េត: ខែអត់ចាំ ។

ខស្នាន: ពាក់កណ្តាល៧៨ ដើម ឬចុងឆ្នាំ៧៨?

ម៉េត: អត់បានចាំ ។ កាលនោះ ខ្ញុំមានតែរឿងគេចខ្លួន កុំអោយឃើញមុខ ខ្លាចគេចាប់ដាក់ ដែរ ។

ខស្នាន: មានបានឃើញមុខគ្នាទេ?

ម៉េត: ឃើញ ។

ខស្នាន: មាននិយាយអីដាក់គ្នាទេ?

ម៉េត: អត់ អត់មាននិយាយអីទេ ។

ខស្នាន: ចុះគាត់?

ម៉េត: គាត់ក៏អត់ហ៊ាននិយាយដែរ?

ខស្នាន: ចុះក្រៅពីភី?

ម៉េតៈ  ក្រៅពីភី អត់ដែលស្គាល់ ។

ខស្មានៈ ហេតុអីបានជាចាប់ភីនោះទៅ?

ម៉េតៈ  ខ្ញុំវាអត់រឿងថាពាក់ព័ន្ធខ្មែរណាអីណា អត់ដឹង ។

ខស្មានៈ ចាប់ពីកន្លែងណាទៅ?

ម៉េតៈ  មិនដឹងជាចាប់ពីកន្លែងណាទៅ ។

ខស្មានៈ ហើយមុនចាប់គាត់ ភីនោះធ្វើអ្វីដែរ?

ម៉េតៈ  ខ្ញុំអត់ដឹងដែរ ។ កាលហ្នឹងខ្ញុំធ្លាប់នៅជាមួយគាត់កាលជំនាន់សង្គ្រាម៧៣-៧៤ ។

ខស្មានៈ ភីជាប់នៅកន្លែងនោះរយៈពេលប៉ុន្មានបានយកចេញទៅ?

ម៉េតៈ  ហេ មិនដឹងប៉ុន្មានថ្ងៃទេ ខ្ញុំភ្លេចទៅ ។

ខស្មានៈ ប្រហែលមើល?

ម៉េតៈ  ប្រហែលកន្លះខែ ។

ខស្មានៈ អ្នកណាអ្នកនាំគាត់ចេញទៅ?

ម៉េតៈ  អត់ដឹង ។ស្រាប់តែបាត់គាត់តែម្តង ។

ខស្មានៈ ហើយក្រោយ៧៩ មានឃើញភីទេ?

ម៉េតៈ  អត់ ។

ខស្មានៈ ភីមានស្រុកកំណើតនៅណា?

ម៉េតៈ  អត់ស្គាល់ទៀតណា៎ ។ កាលនោះ ខ្ញុំមិនដឹងថាស្រុកកំណើតគាត់នៅណាទេ ព្រោះខ្ញុំជា និរសាគាត់ ហើយខ្ញុំផ្លាស់ពីបងភីមកវាច្រើនតពេកណា៎ ។

ខស្មានៈ ពូមានដែលគេឃើញគេយកអ្នកទោសទៅសួរចម្លើយទេ?

ម៉េតៈ  អត់ឃើញទេ ឃើញតែអ្នកទោសដែលគេសួរចម្លើយរួចហើយ ។

ខស្មានៈ ឃើញយ៉ាងម៉េច?

ម៉េតៈ  ពេលខ្ញុំយកបាយអោយ ទទួលឃើញគេបណ្តើរយកមកវិញ ឃើញកន្ទួលខ្នងកន្ទួលអី បែក ឈាមបែកអី ។

ខស្មានៈ អ្នកណាអ្នកបណ្តើរមកវិញ?

ម៉េតៈ  កាលនោះវាច្រើនដែរ តែវាស្លាប់វិញក៏អស់ច្រើនដែរ ។

ខស្មានៈ ឈ្មោះអី?

ម៉េតៈ អាហេង ម៉ានហ្នឹងក៏វាអ្នកបណ្ដើរដែរ ។

ខស្មានៈ ម៉ានណា?

ម៉េតៈ ម៉ានចាម នៅបារ៉ែន រាងស្គម ។

ខស្មានៈ ក្រៅពីហេង ម៉ាន មានអ្នកណាទៀត?

ម៉េតៈ ប៉េងអីហ្នឹង ។

ខស្មានៈ មានអ្នកណាទៀតទេ?

ម៉េតៈ ក្រៅពីហ្នឹងច្រើនតែអ្នកមកពីកំពង់ឆ្នាំង ។

ខស្មានៈ មានស្គាល់ឈ្មោះទេ?

ម៉េតៈ ស្គាល់ អាឈិន អាអុន មិនដឹងអ្នកណាទៀតទេក្មេងៗ ។

ខស្មានៈ ពូរាប់ឈ្មោះប៉ុន្មាននាក់ខាងលើហ្នឹងណា៎ តើគាត់មានតួនាទីអី គាត់ធ្វើការអី?

ម៉េតៈ អាហ្នឹងគេសុទ្ធតែប្រធានក្រុម មេពួកអីហើយ ហើយគណៈកង ។

ខស្មានៈ គេហៅក្រុមអី កងអី ក្រែងមានឈ្មោះគេដែរ មិនចឹង?

ម៉េតៈ និយាយទៅប្រធានក្រុមខាងសួរចម្លើយហ្នឹងហ្មង ហើយប្រធានកង ។ ប៉ុន្តែអាហេងហ្នឹង គេយកវ៉ៃចោលដែរហ្នឹង ។

ខស្មានៈ ចុះម៉ានធ្វើស្អីដែរ?

ម៉េតៈ ម៉ានម្នាក់ហ្នឹងកាលនោះជាប្រធានក្រុមបណ្ដោះអាសន្នផស់គេដែរ ប្រធានក្រុមខាងសួរចម្លើយ ។

ខស្មានៈ ពូមានដែលឮអ្នកទាំងប៉ុន្មាននាក់ហ្នឹងមានដែលនិយាយទេថា មូលហេតុអីបានជាសួរម្លើយគេ?

ម៉េតៈ អត់ដឹង ដល់ទៅអញ្ចឹង ។ ខ្ញុំគ្រាន់តែដើរទៅឃើញអញ្ចឹង ។

(ប្ដូរកាសែ្សតទៅខាងB)

ខស្មានៈ អ្នកប៉ុន្មាននាក់ដែលពូបានរាប់ឈ្មោះថាជាប្រធានក្រុម ប្រធានកង តើពួកគាត់ជាកម្មាភិបាលខ្មែរក្រហមឬយ៉ាងណា?

ម៉េតៈ ហ៊ឺ ដល់កន្លែងហ្នឹងខ្ញុំមិនដឹងឆ្លើយថាម៉េច ខ្ញុំអត់ចេះឆ្លើយ ។

ខស្មានៈ អ្នកណាគ្រប់គ្រងអ្នកហ្នឹង?

ម៉ែតៈ អាហ្នឹងមានតែពួកអាឌុច អាហ៊ិអីហ្នឹង ពួកគេសុទ្ធតែមេៗកន្ទ្រាញហ្នឹង ពួកគេគ្រប់គ្រង ពួកហ្នឹងជាអ្នកដឹកនាំ ។

ខស្នានៈ ក្រៅពីតាតួនមានស្គាល់អ្នកណាទៀតទេ?

ម៉ែតៈ ខ្ញុំអត់ អត់ទេ ។

ខស្នានៈ ពូមានអ្នកណាផ្សេងទៀតដឹងរឿង ឃើញដូចពូអញ្ចឹងទេ?

ម៉ែតៈ ខ្ញុំវាអត់មានចាប់អារម្មណ៍ថាគេដឹង ឬមិនដឹង ។

ខស្នានៈ ពូដឹងថា ម៉ាន ហេង ឈិន និងប៉ុន្មាននាក់ទៀតដែលពូរាប់ឈ្មោះអំបាញ់មិញហ្នឹងណា តើពួកគាត់ធ្វើនោះទទួលបញ្ជារពីអ្នកណា?

ម៉ែតៈ ទទួលបញ្ជារពីឌុច ប៉ុន អាណាច្រើនណាស់ សុទ្ធតែពួកម៉ោពីលើៗម៉ោ ។

ខស្នានៈ មានដែលឃើញរបាយការណ៍សរសេរពីរឿងសួរចម្លើយទេ?

ម៉ែតៈ អត់ៗ គេអត់អោយយើងបើកមើល អត់អោយយើងឈរមើលគេទេ ។ ទោះបីគេអោយ ខ្ញុំមើលក៏ខ្ញុំមើលអត់ស្គាល់អក្សរដែរ ព្រោះខ្ញុំអត់ចេះ ។

ខស្នានៈ ពូ ខ្ញុំចង់ដឹងរឿងសាសនាម្តង ។ ក្នុងចន្លោះថ្ងៃ១៧ មេសា ៧៥ ដល់៦ មករា ៧៩ បីឆ្នាំប្រាំបីខែម្ភៃថ្ងៃហ្នឹងណា៎ តើពូបានឃើញអ្នកណាម្នាក់ធ្វើបាបមនុស្សម្នាក់ដោយសារតែមូលហេតុសាសនា ដូចជាមិនអោយកាន់ប្រតិបត្តិសាសនាដែរឬទេ?

ម៉ែតៈ អត់ ។

ខស្នានៈ ដូចថាចាប់ផ្សឹកលោកសង្ឃ មិនអោយចាមបួស ព្រោះចាមមានខែត្រូវបួស មានដែល ឃើញ ឬដឹងរឿងហ្នឹងទេ?

ម៉ែតៈ អត់ដែលដឹងទេ ។

ខស្នានៈ សុំសួរសំណួរមួយទៀត ។ នៅចន្លោះពេលហ្នឹងណា ១៧ មេសា ៧៥ ដល់៦ មករា ៧៩ ពូដែលឃើញអ្នកណាម្នាក់បំផ្លាញសម្បត្តិវប្បធម៌ទេ? យល់ទេ សម្បត្តិវប្បធម៌ ដូចជា ប្រាសាទជារូបចំលាក់ពីបុរាណ ហៅថាសម្បត្តិវប្បធម៌ ។

ម៉ែតៈ នៅដំណាក់កាលខ្ញុំដូចអត់ដែលឃើញទេ ។

ខស្នានៈ ពូក្នុងជំនាន់ហ្នឹង អំឡុងពេលដែលខ្ញុំនិយាយអំមិញហ្នឹង មានដែលឃើញអ្នកណាម្នាក់ ហាមឃាត់អ្នកណាម្នាក់មិនអោយមានកូនដែរទេ?

ម៉េតៈ  អត់ដឹងទេដល់អញ្ចឹង ។

ខស្មានៈ ខ្ញុំសួរពីលោកពូផ្ទាល់ ។  គឺចន្លោះពីថ្ងៃ១៧មេសា៧៥  ដល់ថ្ងៃ៦មករា៧៩  តើពូមានអ្នកណាម្នាក់គម្រាមកំហែងលោកពូទេ ឬក៏ធ្វើបាបលោកពូផ្ទាល់?

ម៉េតៈ  អាហ្នឹងមាន ។

ខស្មានៈ មានយ៉ាងម៉េច?

ម៉េតៈ  កាលហ្នុងបើយើងធ្វើអីខុសឆ្គងគេពិនិត្យប្រវត្តិរូប ។

ខស្មានៈ ចុះលោកពូផ្ទាល់?

ម៉េតៈ  គម្រាមកំហែងខ្ញុំហ្នឹងវាពីរសារហើយ ។

ខស្មានៈ ឆ្នាំណា?

ម៉េតៈ  ឆ្នាំ៧៦មួយសារ  កាលនៅកន្លែងជិតផ្សារថ្មី  កន្លែងនោះហៅថាគុកដាំដេង ។  កន្លែងនោះខ្ញុំធ្វើអោយរួចអ្នកទោសមួយ ។

ខស្មានៈ ដាំដេងនៅមិនមែនជា ស-២១ទេហ្អេ?

ម៉េតៈ  អាហ្នឹង  បើនិយាយទៅ  ស-២១ដែរ  ប៉ុន្តែ  គេទើបប្រកាស់អោយដឹងថា  ស-២១  នៅទួលស្លែងនេះវិញ ។

ខស្មានៈ កន្លែងណាគុកដាំដេង?  ម្តុំណាដែរ?

ម៉េតៈ  នៅជិតផ្សារថ្មី ។  ខ្ញុំដូចជាភ្លេចទៀតរឿងទីក្រុង ។

ខស្មានៈ ខាងណាផ្សារថ្មី?

ម៉េតៈ  អត់ដឹង ។

ខស្មានៈ ហើយចុះរឿងមួយទៀត  ទីពីរ?

ម៉េតៈ  គេថាខ្ញុំធ្វើការមិនល្អ  គេពិនិត្យប្រវត្តិរូបទៅមានបងពាក់ព័ន្ធមុនឆ្នាំ៧៥  កាលមុន៧៥  គាត់(បង) នៅធ្វើនំប៉័ងគេហ្នឹងណា  នៅត្រង់ផ្សារថ្មីយើងហ្នឹងណា  កាលពីសង្គម ។  ដល់ដឹងអញ្ចឹងការងាររបស់ខ្ញុំត្រូវមកធ្វើស្រូវធ្វើអី  និយាយរួមទៅ  ខ្ញុំចាំតែថ្ងៃគេក្របួចដែរហ្នុង ។  ហើយបងគេមកបាត់ម៉ោមួយហើយ  ខ្ញុំក្តីតែគេថា ។

ខស្មានៈ ពិនិត្យប្រវត្តិរូបហើយយ៉ាងម៉េច?  ក្រែងនៅតែធ្វើការដដែលទេហ្អេ?

ម៉េតៈ  ពិនិត្យហើយគេអោយខ្ញុំមកនៅបឹងទំពុន ។

ខស្នាន: មកធ្វើអីនៅបឹងទំពុន?

ម៉េត: មកធ្វើស្រូវ ។

ខស្នាន: នៅឆ្នាំណា?

ម៉េត: ឆ្នាំ៨៨ អូ៧៨ ។

វណ្ណៈ: បងពូឈ្មោះអីដែរ?

ម៉េត: ម៉េង ។

ខស្នាន: ពូពេលមកធ្វើស្រូវបឹងទំពុន ពូពិបាក ឬក៏ស្រួលយ៉ាងម៉េច? ការរស់នៅរបស់លោក ពូ ។

ម៉េត: គេអោយទៅធ្វើស្រូវ និយាយថាអរជាងនៅហ្នុងទៀត ។

ខស្នាន: ហេតុអីបានអញ្ចឹង?

ម៉េត: មូលហេតុបើនៅក្នុងខុសម៉ាបន្តិច គេយកយើងដាក់ទោស ដាក់ទារុណកម្មយើងហើយ ហើយបើយើងធ្វើស្រូវ យើងបានដើរហើរជាមួយកុមារជាមួយអីអីចឹងទៅ ដើរមើល ថែទាំស្រូវ រកអីហូបបានណា៎ ។ ដល់យើងចូលក្នុងហ្នុងដូចជាប់គុកដែរចឹង ។

ខស្នាន: ចឹងបានន័យថាមកធ្វើស្រូវស្រួលជាង?

ម៉េត: បាទ ស្រួលជាង ហើយសេរីភាពក៏ល្អជាង ។

ខស្នាន: ចុះពូនៅស-២១ ថាពិបាកយ៉ាងម៉េច និយាយអាកន្លែងពិបាកនោះមើ?

ម៉េត: ពិបាកថាឃើញទឹងភ្នែកពិបាកមើល ហើយពេលអោយបាយអោយទឹកអី វាពិបាក ។ យើងមិនអាចដើរហើរបាន ។

ខស្នាន: ពិបាកត្រឹមដែរដើរហើរមិនបាន?

ម៉េត: បាទ ។

ខស្នាន: ចុះហូបចុកស្លៀកពាក់អី?

ម៉េត: អត់អីទេ ។

ខស្នាន: ខ្ញុំចង់ដឹងថាអ្នកណាបញ្ជូនពូអោយទៅធ្វើការនៅស-២១?

ម៉េត: កាលហ្នឹងនិយាយទៅតាណាត ចុះកាលហ្នុងគាត់ដើរប្រមូលអាដែងនិរសារ ។ តាណាតអ្នកអោយទៅ ។

ខស្នាន: ឆ្នាំណាពូ?

ម៉េតៈ  ឆ្នាំ៧៦ ។

ខស្មានៈ ខែណា?

ម៉េតៈ  អត់ដឹងខែ ។

ខស្មានៈ ៧៦ នោះទៅទួលស្លែង ឬក៏នៅគុកដាំផេង?

ម៉េតៈ  នៅកន្លែងដាំផេង ។

ខស្មានៈ ហើយឆ្នាំចិតសិបប៉ុន្មានបានមកនៅទួលស្លែង?

ម៉េតៈ  មិនដឹងជាចិតប៉ុន្មានទេ ភ្លេចហើយ ខ្ញុំគេចេះតែបញ្ជូនឡប់ឡែបន្តិចមកស្រូវ ។

ខស្មានៈ នឹកមើល ។

ម៉េតៈ  មើល៧៦ ខ្ញុំនៅកន្លែងដាំផេង ៧៧ខ្ញុំដូរមកនៅទួលស្លែង ។

ខស្មានៈ អញ្ចឹង៧៧?

ម៉េតៈ  បាទ ។

ខស្មានៈ ខែណា?

ម៉េតៈ  អត់ដឹងខែទេ ។

ខស្មានៈ ហើយក្រោយមកទៀត ពូទៅណាទៀត?

ម៉េតៈ  បន្ទាប់ពីហ្នឹងមក គេអោយខ្ញុំមកធ្វើស្រូវ ៧៨នេះវិញ ។

ខស្មានៈ ខែណា? ដូចថាដើមឆ្នាំ ពាក់កណ្ដាល ឬចុងឆ្នាំ៧៨?

ម៉េតៈ  អត់ចាំទៀតមិនដឹងខែណាអីណាទេ បើតែថ្ងៃខែខ្លួនឯងអត់ចាំផងហ្នឹង ។

ខស្មានៈ ពីណាអ្នកផ្លាស់ពូពីដាំផេងមកទួលស្លែង?

ម៉េតៈ  អាហ្នឹងខុចហ្នឹងហើយ ។

ខស្មានៈ ហើយអ្នកណាបញ្ជូនពូអោយទៅធ្វើស្រែឆ្នាំ៧៨?

ម៉េតៈ  អាហ្នឹងពួកអាប៉េងអីហ្នឹង អាហ៊ិអីហ្នឹង ។

ខស្មានៈ ប៉េងធ្វើអី?

ម៉េតៈ  ប៉េងអ្នកខាងសួរចម្លើយខាងចាប់អីហ្នឹង ។

ខស្មានៈ នៅពេលដែលមកធ្វើស្រែនៅបឹងទំពុន មកតែម្នាក់ពូទេ ឬមានអ្នកផ្សេងទៀតមកដែរ?

ម៉េតៈ  មានខ្ញុំម្នាក់ គេយកខ្ញុំដាក់ជាមួយកុមារ ។

ខស្មាន: អ្នកណាអ្នកនាំពូមកផ្ទាល់ហ្នឹង?

ម៉ែត: អ្នកនាំខ្ញុំមកអានេះទេ អាស្ទីបើកឡាននោះ ។

ខស្មាន: ឈ្មោះអី?

ម៉ែត: ដឹងឈ្មោះអី ។

ខស្មាន: នៅរស់ទេសព្វថ្ងៃ?

ម៉ែត: អត់ដឹងទៀត អត់ដឹងថារស់ឬស្លាប់អីទេសព្វថ្ងៃហ្នឹង ។

ខស្មាន: ពូ! មានអ្នកខ្លះដែលដឹងរឿងពូ ដូចថាដឹងថា៧៦ពូនៅដាំដេង ៧៧ពូនៅស-២១ ៧៨ ពូមកនៅបឹងទំពុនហ្នឹងណា? តើពីដឹងរឿងរបស់ពូ?

ម៉ែត: ដឹងមានតែបងខ្ញុំនៅព្រែកស្តីអីហ្នឹង ។

ខស្មាន: មិនដឹងដោយសារពូនិយាយប្រាប់ទេ គឺអ្នកដែលនៅជាមួយគ្នា ហើយឃើញលោកពូកាលពីជំនាន់នោះ?

ម៉ែត: អត់ដឹង ក្រែងលោខ្ញុំនឹកមិនឃើញយ៉ាងម៉េចអីយ៉ាងម៉េចទេ ។

ខស្មាន: ពូ ក្នុងពេលបញ្ជូនពូពីកន្លែងមួយទៅកន្លែងមួយ មានធ្វើរបាយការណ៍ទេ?

ម៉ែត: ដូចអត់មានធ្វើអីទេ គ្រាន់តែដឹងថាគេថាយើងសមាសភាពមិនល្អ ។

ខស្មាន: ពូមានដែលឃើញគេសរសេរប្រវត្តិរូបរបស់លោកពូទេ?

ម៉ែត: អត់ ។

ខស្មាន: និយាយពីរឿងកុមារ ពូដែលដឹងថាមានការជម្លៀសកុមារពីកន្លែងមួយ ទៅកន្លែងមួយទេ? ដូចថាចាប់បង្ខំកូនអោយចេញពីឪពុកម្តាយ ។

ម៉ែត: អត់ ។

ខស្មាន: ពូនៅចន្លោះពេលហ្នឹង ១៧មេសា៧៥ ដល់៦មករា៧៩ហ្នឹង ពូបានឃើញអ្នកណាម្នាក់បង្ខំអ្នកណាម្នាក់ទៀតអោយធ្វើការនៅកន្លែងមួយដែលខ្លួនមិនពេញចិត្តទេ ក្រៅពី លោក ពូ ខ្ញុំដឹងថាលោក មិញនិយាយថា អត់ចង់ទៅនៅទួលស្លែង ស្រាប់តែគេបញ្ជូនលោកពូឲ្យ ទៅនៅណឹង ចុះក្រៅពីលោកពូមានដឹងថាអ្នកណាទៀតគេចាប់បង្ខំ?

ម៉ែត: ចូលទៅណឹង

ខស្មាន: បាទ ឬក៏អ្នកទាំងអស់ពេញចិតនឹងទៅ លើកកែងតែពីម្នាក់ដែលមិនពេញចិត្តនឹងការងារ

ម៉េត: រឿង តែគេបង្ខំរឿងយើងមិនអាចរបកែកបាន បើនិយាយឲ្យរួមទៅ អត់មាន អ្នកណាចង់ទេទៅអញ្ជើង

ខស្មានៈ ទាំងអស់ណឹង ហេតុអីបានពូថាអញ្ជើង

ម៉េតៈ បាទ មា៉ ពួកខ្ញុំគេប្រមូលតាម គេដក មិនដឹងគេដកទៅណាអីណា យើងអត់ដឹង យើងអត់ថាគេដកយកទៅណាមកណាអីដឹងដឹង គ្រាន់ទៅដល់វា៉ក់អើភ័យខ្លួន

ខស្មានៈ ចុះអ្នកផ្សេងទៀតក្រែងលោកគាត់ពេញចិត្តនឹងធ្វើការងារណឹង អ្នកផ្សេងៗទៀត

ម៉េតៈ អ្នកផ្សេងខ្ញុំអត់ហ៊ានសន្និដ្ឋានថាក្នុងចិត្តគេម៉េចៗអត ដឹងចិត្តគេចិត្តចង់ឬមិនចង់ បើថាចិត្តខ្ញុំអត់ចង់ទេ ព្រោះអីខ្ញុំជាអ្នកធម៏អារ្យដែរ ឲ្យខ្ញុំទៅចង់ធ្វើអញ្ជើងហីយើង ប្រកែកញ៉ាញគេដាក់យើងត្រឹមតឡូវណឹង ចឹងអត់ចង់ទេ ខ្ញុំមិនចង់ទេ។ សុទ្ធតែពូជធម៏អារ្យ ហីឲ្យខ្ញុំទៅធ្វើចឹងៗខ្ញុំទៅអត់រួចដែរ ប៉ុនវាជៀសមិនរួច ណាមួយខ្ញុំនឹកឃើញប្រវត្តិរូបខ្ញុំក៏មិនល្អ វាមិនទៅគេយកតែវណ្ណៈភាពក្រីក្រ អាកន្លែងណឹងគេយកអ្នកលុិតល្ងង់ ហីវណ្ណៈភាព យើងដូចជាអីណានាយទុនចឹង គេមានសួរអី ធម្មតាតាមខ្ញុំឮដំណឹងសុទ្ធតែវណ្ណៈភាព កណ្តាល វណ្ណៈភាបលើអីចឹងគិតទៅតាមនេះ មានអីក៏មិនសល់ដែរ..?

ខស្មានៈ ខ្ញុំសុំសួរតិចទៀត ពូមានដឹងពីកាជម្លៀស ពូ ក្នុងចន្លោះឆ្នាំណឹងមានដឹងថា ពូបានឃើញ ឬបានដឹងថា មានគេមកឲ្យនរណាម្នាក់ចេញពីភូមិខ្លួនឯងទៅកន្លែងណាមួយដោយបង្ខំចិត្ត ទាំងពីផ្ទាល់ខ្ញុំចង់និយាយថា មិនបាច់បង្ខំឲ្យទៅធ្វើការអីទេ ដូចថាពូនៅភូមិនេះឬក៏បងប្អូន ពូនៅភូមិនេះហើយមានជម្លៀសទៅភូមិណាផ្សេងទៀតទេ។

ម៉េតៈ អត់។

ខស្មានៈ ចឹងនៅក្នុងស្រុកភូមិពូអត់មានជម្លៀសទេ?

ម៉េតៈ ស្រុកភូមិនេះ?

ខស្មានៈ បាទ។

ម៉េតៈ ខ្ញុំពិបាកដែរព្រោះអីខ្ញុំកាលនៅទ័ពនៅអី ដល់អញ្ជើងអត់សូវដឹងកន្ទុកកន្លៀនជម្លៀសទៅណាអីណាដល់គេមកវិញ ដូចថាបងប្អូនគេជម្លៀសទៅ១៥៤ មានទៅណេះណោះ ដល់មកជួបគ្នាដូចបងខ្លះគេទៅខាងវាលវេញអីនោះ ដល់ចឹងខ្ញុំអត់បានពិនិត្យពិច័យអី យកតែមា៉រួចខ្លួនឲ្យតែ។

ខស្ចាន: ខ្ញុំចង់សួរពីរឿងស្រ្តី ពូដែលឃើញ ក្នុងចន្លោះពេលណឹងដែលឃើញអ្នកណាចាប់រំលោភ ស្រ្តី ស្រីណឹងមិនស្រឡាញ់អ្នកណឹងទេ ប៉ុន្តែគេចាប់បង្ខំ ពូដែលឃើញទេ?

ម៉េត: អត់ដែល ។

ខស្ចាន: ចុះពូអត់ដែលដែរ ។

ម៉េត: ពុចេះតែពុថា ទាល់តែឃើញផ្ទាល់បានខ្ញុំហ៊ាននិយាយ បើអត់ឃើញផ្ទាល់ខ្ញុំអត់ហ៊ាននិយា យទេ ទាល់តែផ្ទាល់នឹងភ្នែក ។

ខស្ចាន: មួយទៀត សំណួរមួយទៀតសួរថា តើពូដែលឃើញអ្នកណាម្នាក់ធ្វើបាបអ្នកណាម្នាក់ទៀត ដោយសារតែមកពីរឿងពូជសាសន៍ឬក៏រឿងនយោបាយអី ដូចថាសាសន៍អ្នកឯងចាម អ្នកឯង ណឹងជាយួន ជាចិន អ្នកឯងជាខ្មែរដែលឃើញទេ ។ ពូនៅស២១ណឹងក៏ដោយ គេចាប់ អ្នកណឹងមកពីគេថា មកពីអ្នកណឹងចេះៗ

ម៉េត: និយាយទៅខ្ញុំ និយាយសព្វថ្ងៃណឹងចេះហ្នឹង អារឿងខ្ញុំ អត់ដឹង ខ្ញុំសុខចិត្តដាំដើមគ ទុករឿងអ្នក ណាអ្នកណី ក៏ខ្ញុំធ្វើមិនដឹង ឲ្យពិបាកណាស់រឿងចឹងៗ ខ្ញុំពិបាកក្នុងខ្លួនគេសួរ មកថា ដល់ពេល ទៅកន្លែងណាខ្លះ រកធ្វើដឹងមិនកើត ចឹងបានថាខ្ញុំសុខចិត្តដាំដើមគ លែងមាត់ លេង ក ។

ខស្ចាន: បាទ អញ្ចឹងល្អហើយ ប៉ុន្តែការងារដែលខ្ញុំជួបពូនិយាយណឹង ពូនិយាយទៅដើម្បីឲ្យកូន ខ្មែរ យើងជំនាន់ក្រោយណឹងកុំធ្វើតាមជានណឹង ។

ម៉េត: អើ ខ្ញុំអរគុណច្រើនហើយ ។

ខស្ចាន: ពូនិយាយថាពូមិនចង់ទៅធ្វើ កន្លែងណឹង គេចាប់បង្ខំពូ គឺមានន័យទូលំទូលាយណាស់ សំរាប់ អ្នកដឹកនាំក្រោយៗទៀត អ្នកដឹកនាំក្រោយទៀត ។

ម៉េត: ខ្ញុំមិនចង់ទៅដើរផ្តេសផ្តាស

ខស្ចាន: ចុះពូរឿងជាតិសាសន៍ពូអត់ដែលឃើញទេ គេធ្វើបាបអ្នកណឹងគេចាប់អ្នកណឹង ដោយសារមក ពីពូជសាសន៍ខុសគ្នា ។

ម៉េត: ដែលឃើញពីបច្ចុប្បន្ន ។

ខស្ចាន: មិនមែនបច្ចុប្បន្នទេ ខ្ញុំសួរពេលនោះ អត់ឃើញទេ ។

ម៉េត: កាលពេលនោះ និយាយទៅវា រកសូម្បីតែបារាំក៏មិនស្គាល់ដែរខ្ញុំ ។

ខស្មានៈ ពូ ៧៥ដល់ ៧៩ក្រោយបែភ្នំពេញ មកដល់ ឆ្នាំ៧៩ ៦មករា៧៩ណឹង ពូដែលទៅច្បាំងគ្នាទេ ។

ម៉េតៈ អត់ ។

ខស្មានៈ អត់ទេ ។

ម៉េតៈ ដែលគេយកខ្ញុំទៅ ក៥ ។

ខស្មានៈ អត់ទេ ជំនាន់ក៥ ក្រោយ៧៩ទេ ពេលបីឆ្នាំ៨ខែ ២០ថ្ងៃ ។

ម៉េតៈ មុន៧៩ ។

ខស្មានៈ ពីថ្ងៃ ១៧ មេសា ៧៥គឺថ្ងៃរំដោះភ្នំពេញ មកទល់ថ្ងៃ៦ មករា ៧៩ ជាថ្ងៃដែលខាង គណបក្សប្រជាជនរំទីក្រុងភ្នំពេញ បើរបបខ្មែរក្រហមក្នុងចន្លោះពេលណឹង ពូមានដែលទៅធ្វើសង្គ្រាមទេ ។

ម៉េតៈ កាលណឹងខ្ញុំបានរត់ទៅលិច ដល់រត់ទៅលិចណឹងនឹកឃើញថា យោសនានយោបាយ បេះតែខ្លាចហើយ បេះតែខ្លាចដូចថាវៀតណាមមកចឹង បេះតែរត់ទៅ ថារត់ទៅណឹងបេះ តែនឹកឃើញបោលឪពុកម្ដាយមិនដឹងស្លាប់ឬរស់ក៏មិនដឹង នឹកឃើញថានឹកឃើញធ្វើមិន ធ្វើចូលទៅមកផ្ទះចូលទៅ បាញ់គ្នាជាមួយយួន ខ្ញុំមិនបានទេ បានជួបអ្នកនៅ ព្រែកស្ដីដែរ នោះ ហើយគេថាយីអាអូនឯងនៅណា ខ្ញុំថាខ្ញុំនៅព្រែកស្ដី ខ្ញុំកូនចៅ បងឯង ខ្ញុំប្រាប់តាមដំណើរ បានមកជាមួយគាត់មក ។

ខស្មានៈ មុនពេលណឹងអត់មានច្បាំងទេ?

ម៉េតៈ អត់ ។

ខស្មានៈ ពូឃើញវ៉ៃ វ៉ៃពេលណា វ៉ៃ មុន៧៥?

ម៉េតៈ កាលខ្ញុំវ៉ៃហ្នឹង ៧៣, ៧៤, ៧៥ ណឹងចប់ហ្នឹង ។

ខស្មានៈ ចុះ៧៦, ៧៧, ៧៨ មានដែលទៅច្បាំងជាមួយអ្នកណាទេ?

ម៉េតៈ អត់ដែលទេ ។

ខស្មានៈ ពូ ខ្ញុំសុំសួរមួយទៀត តើមានដែលអ្នកណាមួយដាក់បញ្ជារលោកពូអោយធ្វើបាបអ្នកណា ម្នាក់ទេ?

ម៉ែតៈ  អត់ ។ ហើយកាលនៅសង្គ្រាមជាមួយ លន់ នល់ ធ្វើម៉េច ទល់មុខគ្នាហើយ ចេះតែលេងហើយ ។

ខស្មានៈ ប៉ុន្តែខ្ញុំចង់ដឹងក្រោយ៧៥ ក្រោយបែកភ្នំពេញ ។

ម៉ែតៈ  ក្រោយ៧៥នេះគេអត់អោយខ្ញុំធ្វើអីចឹងទេ ព្រោះគេអត់ទុកចិត្តខ្ញុំ ។ ណាមួយ បើគេអោយធ្វើខាងណឹងដូចខ្ញុំជម្រាបខាងលើ ខាងសួរចម្លើយ ខាងចាប់ខាងចង ។ ចុះបើយើង ចាប់គេមិន ជាប់ គេទុកចិត្តអីយើង ។ បើសួរចម្លើយគេ គេឆ្លើយមកមិនដឹងសរសេរ យ៉ាងម៉េច(អត់ ចេះអក្សរ) ។ ទីពីរ គេអោយយើងយាម ដឹងតែពីយាម យាមមិនស្រួល ។

ខស្មានៈ ពូកាលជំនាន់នោះមានចេះអានទេ?

ម៉ែតៈ  ចេះអានតិចៗ កាលពីដើមខ្ញុំរៀនថ្នាក់ទី១២ហ្នឹង ។

ខស្មានៈ ពូ កាលជំនាន់ហ្នឹង ពូមានដែលបានអាន ឬស្តាប់សេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំខ្មែរក្រហមទេ?

ម៉ែតៈ  ស្តាប់ ប៉ុន្តែស្តាប់ហើយមិនដឹងជាទៅឯណាអស់ទេខ្ញុំ ។

ខស្មានៈ ស្តាប់យ៉ាងម៉េច?

ម៉ែតៈ  ស្តាប់ដូចគេនិយាយពីរឿងឯកសារអីណា គេណែនាំអោយយើងពង្រឹងគោលជំហរសតិអារម្មណ៍អីចឹងណា៎ ។

ខស្មានៈ ស្តាប់នៅកន្លែងណា?

ម៉ែតៈ  ស្តាប់នៅកន្លែងរៀន កាលនោះដូចរៀននយោបាយ នៅផ្សារថ្មីអីហ្នឹង ។

ខស្មានៈ នៅពេលណា?

ម៉ែតៈ  កាលហ្នឹងនៅ៧៦ ៧៥ ។

ខស្មានៈ អ្នកណាអ្នកចេញសេចក្តីថ្លែងការណ៍ហ្នឹង?

ម៉ែតៈ  និយាយទៅដូចតាពីន តាណាត អីហ្នឹង ។

ខស្មានៈ សេចក្តីថ្លែងការណ៍ហ្នឹងនិយាយថាម៉េច? គ្រាន់តែបញ្ជាក់ន័យគោលៗ ។

ម៉ែតៈ  គេអោយយើងពង្រឹងគោលជំហរ សតិអារម្មណ៍ កុំអោយយើងវង្វេងវាយទៅណា កុំអោយ ភ្លើតភ្លើនតាមមនោសញ្ចេតនា កុំអោយសម្ភារៈអូសទាញ កាលចូលរៀន ៧៥ ហ្នឹងណា ។ ខ្ញុំភ័យទៀតណា៎ ណាមួយអត់ចេះរឿងទ្រឹស្តី អក្សរក៏អត់ចេះ ។

ខស្នានៈ ពូ, អ៊ីដែលលោកពូបាននិយាយខាងលើនេះ តើលោកពូហ៊ានបញ្ជាក់ថាជារឿងពិត ឬក៏មានលើសត្រង់ណា ខ្វះត្រង់ណាទេ?

ម៉េតៈ ហ្នឹងជារឿងពិត ។

ខស្នានៈ ពូ ហ៊ាននិយាយថា ហ្នឹងជារឿងពិតរបស់ពូ? ពូបានឃើញ បានឮ បានដឹងអញ្ចឹង មែន?

ម៉េតៈ បាទ ។

ខស្នានៈ អញ្ចឹង ខ្ញុំអរគុណពូច្រើនហើយ ។

ម៉េតៈ ខ្ញុំអត់មានទៅលាក់លៀមរឿងអីចឹង១ទេ ។

ខស្នានៈ បាទ! បាទ! ត្រូវហើយ ។

ម៉េតៈ ហើយមកដល់បច្ចុប្បន្ននេះ ខ្ញុំអត់មានថាទៅណាមកណា ខ្លាចគេអី ព្រោះតែរឿងអញ្ចឹងទេ ។ ប៉ុន្តែគ្រាន់តែខ្ញុំអត់សូវចេះនិយាយ ។

ខស្នានៈ បាទ ។

«ចប់»